## ការចូលរួមជាសាធារណៈនៅក្នុងការប្រជុំគណៈក្រុមប្រឹក្សាភិបាលសាលា-កែសម្រួលឡើងវិញ 8/14/20

គណៈក្រុមប្រឹកស្សាភិបាលសាលានឹងទទួលសិក្ខាកម្មដោយផ្ទាល់និងតាមរយៈអ៊ីមែលសម្រាប់សិក្ខាសាលានិងការប្រជុំនៅថ្ងៃទី១៨-១៩ ខែសីហា។ សិក្ខាកម្មផ្ញើរតាមអ៊ីមែលនឹងត្រូវអានឱ្យស្តាប់ដោយបុគ្គលិកនៅក្នុងពេលប្រជុំ បើសិនជាពេលវេលាអនុញ្ញាតឱ្យ។

### វត្តមានដោយផ្ទាល់ខ្លួននៅក្នុងការប្រជុំក្រុមប្រឹក្សាភិបាល

វាត្រូវបានរំពឹងថា សមាជិកគណៈក្រុមប្រឹក្សាភិបាលការអប់រំ នឹងមានវត្តមាននៅក្នុងការប្រជុំ ក៏ប៉ុន្តែ អនុលោមតាមបទបញ្ជាប្រតិបត្តិរបស់ថៅហ្វាយខេត្ត ហ្គាវិន នូសំ លេខ N-25-20(11) ហើយដែលបានកែឡើងវិញដោយបទបញ្ជាប្រតិបត្តិលេខ N-29-20, សមាជិកគណៈក្រុមប្រឹក្សាភិបាលអាចចូលរួមប្រជុំនិងធ្វើការបោះឆ្នោតពីចម្ងាយតាមរយៈទូរសន្និសិទ បើសិនជាពួកគាត់សម្រេចធ្វើដូច្នោះ។ សមាជិកនៃសាធារណៈជនអាចទស្សនាការប្រជុំក្រុមប្រឹក្សាភិបាលដែលមានបន្តផ្សាយផ្ទាល់ស្របពេលជាមួយគ្នាតាមរយៈវែបសាយខាងក្រោមៈ

lbschools.net/youtube.

ដើម្បីគោរពតាមបទបញ្ជារពីរដ្ឋនិងក្រុង ស្តីអំពីការជួបប្រមូលផ្តុំគ្នាជាសាធារណៈ សមាជិកសាធារណៈជនពុំអាចមកចូលរួមប្រជុំក្រុមប្រឹក្សាភិបាលអប់រំបានឡើយ លើកលែងតែដូចមានការពណ៌នាខាងក្រោមនេះ។

គណៈក្រុមប្រឹក្សាភិបាលអប់រំឱ្យតម្លៃដល់មតិយោបលរបស់សាធារណៈជនហើយលើកទឹកចិត្តឱ្យសមាជិកនៃសាធារណៈជនផ្តល់មតិជាសាធារណៈនៅក្នុងការប្រជុំនេះ។ សមាជិកសាធារណៈណាម្នាក់ដែលចង់បញ្ចេញមតិនៅក្នុងការប្រជុំគណៈក្រុមប្រឹក្សាអប់រំអាចចូលមកក្នុងអគារម្នាក់ម្តងហើយដើរសំដៅទៅមីក្រូហ្វូន នៅពេលគេហៅឈ្មោះគាត់។ រាល់សមាជិកសាធារណៈជន លើកលែងតែបុគ្គលណាដែលបានលើកលែងដោយច្បាប់ ត្រូវតែពាក់ម៉ាសធ្វើពីក្រណាត់គ្របច្រមុះនឹងមាត់ ហើយត្រូវចាកចេញពីសាលប្រជុំភ្លាម បន្ទាប់ពីបានបញ្ចប់ពេលវេលារបស់គាត់ ដើម្បីអនុញ្ញាតឱ្យបុគ្គលបន្ទាប់មកទៀតចូលមកនិយាយម្តង។ វត្តមាននៅក្នុងពេលប្រជុំនឹងត្រូវ កំណត់ឱ្យតែបុគ្គលិកសំខាន់ៗ(ដែលត្រូវពាក់ម៉ាសដែរ)និងសមាជិកសាធារណៈជនដែលនឹងអនុញ្ញាតឱ្យចូលមកម្តងមួយៗនៅក្នុងពេលសម្រាប់ផ្តល់មតិជាសាធារណៈ។ បុគ្គលនៅក្នុងសាលប្រជុំនឹងត្រូវដាក់គម្លាតឱ្យនៅឆ្ងាយពីគ្នាយ៉ាងតិចចម្ងាយ៦ហ្វីទជានិច្ច។

ទីបន្ទាល់ផ្ញើរតាមអ៊ីមែល

បុគ្គលិកនឹងអានឱ្យស្តាប់នូវអ៊ីមែលដែលបានទទួលសម្រាប់មតិយោបល់ជាសាធារណៈយោងទៅតាមនិតិវិធីខាងក្រោម។ មតិគប្បីត្រូវសង្ខេបហើយត្រូវបានសរសេរសម្រាប់អានឱ្យចប់ក្នុងរយៈពេលបីនាទីឬតិចជាង។ មតិណាដែលលើសពី៣នាទី នឹងត្រូវប្រគល់ជូនដល់សមាជិកគណៈក្រុមប្រឹក្សាភិបាលហើយនឹងមានសម្រាប់ឱ្យសមាជិកសាធារណៈជនពិនិត្យមើលនៅពេលគាត់ស្នើសុំ។ សូមចាំថា មតិដែលមិនបានចុះនៅក្នុងកម្មវត្ថុនៃរបៀបវារៈប្រជុំពុំអាចទទួលការឆ្លើយតបនៅក្នុងពេលប្រជុំបានទេ ក៏ប៉ុន្តែគណៈក្រុមប្រឹក្សាភិបាលនឹងស្តាប់ដោយយកចិត្តទុកដាក់ទៅលើមតិយោបល់ទាំងនោះ ហើយជាញឹកញាប់ មតិយោបល់ទាំងនោះក្លាយជាចំណែកមួយនៃការពិភាក្សានៃការប្រជុំគណៈក្រុមប្រឹក្សាភិបាលនៅថ្ងៃក្រោយ នៅពេលដែលមតិយោបល់នោះអាចដាក់បាននៅក្នុងរបៀបវារៈ។ ដោយសារតែយើងតម្រូវ ការស្នើសុំបញ្ចេញមតិឱយកត់សម្គាល់ថាតើមតិនោះមានបានចុះនៅក្នុងរបៀបវារៈដែរឬទេ ហើយបើមាន តើកម្មវត្ថុមួយណានៅក្នុងរបៀបវារៈដែលត្រូវពិភាក្សា។ មានតែមតិយោបល់ដែលបានទទួលក្រោយពេលរបៀបវារៈត្រូវបានចុះផ្សាយរួចហើយទេទើបអាចយកមកអាននៅក្នុងការប្រជុំបាន។ សមាជិកសាធារណៈជនដែលចង់ធ្វើការបញ្ចេញមតិនៅក្នុងពេលប្រជុំគណៈក្រុមប្រឹក្សាភិបាលគប្បីធ្វើតាមវិធានបទខាងក្រោមនេះ:

### មតិយោបល់សាធារណៈនៅក្នុងពេលប្រជុំបិទទ្វារៈ

រហូតដល់២០នាទីមុនពេលប្រជុំបិទទ្វារ សូមអ៊ីមែលមតិយោបល់ទៅ closed.session.public.comment@lbschools.net នូវមតិយោបល់ដែលត្រូវអានដល់អ្នកដែលមានវត្តមាននៅក្នុងពេលប្រជុំបិទទ្វារ។ រាល់ការបញ្ចេញមតិយោបល់សាធារណៈទាំងអស់ត្រូវចាប់ផ្តើមដោយមានរាយរាប់នូវព័ត៌មានខាងក្រោមនេះដូចតទៅ:

- ឈ្មោះរបស់អ្នកនិងកម្មវត្ថុនៅក្នុងរបៀបវារៈដែលអ្នកចង់និយាយ
- ការប្រជុំបិទទ្វារដែលអ្នកចង់ឱ្យគេអានមតិយោបល់របស់អ្នក

**មតិយោបល់សាធារណៈនៅក្នុងកម្មវត្ថុដែលបានចុះនៅក្នុងរបៀបវារៈនៃពេលប្រជុំបើកទ្វារជាសាធារណៈ:**

រហូតដល់២០នាទីមុនពេលប្រជុំបិទទ្វារ សូមអ៊ីមែលមតិយោបល់ទៅ open.session.agenda.comment@lbschools.net នូវមតិយោបល់ដែលត្រូវអានដល់អ្នកដែលមានវត្តមាននៅក្នុងពេលប្រជុំបើកទ្វារ។ រាល់ការបញ្ចេញមតិយោបល់សាធារណៈទាំងអស់ត្រូវចាប់ផ្ដើមដោយមានរាយរាប់នូវព័ត៌មានខាងក្រោមនេះដូចតទៅៈ

- ឈ្មោះរបស់អ្នកនិងកម្មវត្ថុនៅក្នុងរបៀបវារៈដែលអ្នកចង់និយាយ
- ការប្រជុំបើកទ្វារដែលអ្នកចង់ឱ្យគេអានមតិយោបល់របស់អ្នក

**មតិយោបល់សាធារណៈនៅក្នុងកម្មវត្ថុដែលពុំបានចុះនៅក្នុងរបៀបវារៈនៃពេលប្រជុំបើកទ្វារជាសាធារណៈ:**

រហូតដល់២០នាទីមុនពេលប្រជុំបិទទ្វារ អ៊ីមែលមតិយោបល់ទៅ open.session.nonagenda.comment@lbschools.net នូវមតិយោបល់ដែលត្រូវអានដល់អ្នកដែលមានវត្តមាននៅក្នុងពេលប្រជុំបើកទ្វារ។ រាល់ការបញ្ចេញមតិយោបល់សាធារណៈទាំងអស់ត្រូវចាប់ផ្ដើមដោយមានរាយរាប់នូវព័ត៌មានខាងក្រោមនេះដូចតទៅៈ

- ឈ្មោះរបស់អ្នកនិងកម្មវត្ថុនៅក្នុងរបៀបវារៈដែលអ្នកចង់និយាយ
- ការប្រជុំបើកទ្វារដែលអ្នកចង់ឱ្យគេអានមតិយោបល់របស់អ្នក

បើអ៊ីមែលរបស់អ្នកពុំមានរាយកម្មវត្ថុច្បាស់លាស់នៅក្នុងរបៀបវារៈដែលអ្នកចង់និយាយបញ្ចេញមតិ វានឹងត្រូវដាក់នៅក្នុងប្រភេទនៃកម្មវត្ថុដែលពុំមានចុះនៅក្នុងរបៀបវារៈ។ បើយើងបានទទួលអ៊ីមែលក្រោយពេលផុតកំណត់ដូចមានរាយខាងលើនេះ យើងនឹងខិតខំអស់ពីសមត្ថភាពដើម្បីអានអ៊ីមែលដែលបានផ្ញើរមកយឺតពេល នៅពេលដែលត្រូវអានមតិយោបល់របស់សាធារណៈជន ក៏ប៉ុន្តែបើផ្ញើរអ៊ីមែលមកមុនពេលផុតកំណត់វានឹងជួយជៀសវាងដល់ការខកខានមិនបានអាននូវមតិយោបល់របស់អ្នក។

បើសិនជាអ្នកស្ថិតនៅក្នុងស្ថានភាពណាមួយដែលរារាំងអ្នក មិនឱ្យមានលទ្ធភាពក្នុងការបញ្ចេញមតិ យោបល់តាមរបៀបទាំងឡាយខាងលើនេះ សូមទាក់ទង Leticia Rodriguez នៅលេខ (562) 997-8240.